# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ០៨៦ ប្រក.ព.ម

# ប្រកាស
# ស្តីពី
# ការកំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ក.គ.ផ.ស.

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា



អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដាកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្រ្តកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីស្តង់ដាកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ២៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលទំនិញនិងសេវា
- យោងសេចក្តីសម្រេចលេខ ៧៦ សសរ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង
- យោងសេចក្តីសម្រេចលេខ១០៨សសរ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងរបស់រាជរដ្ឋាភិបាល
- យោងប្រកាសលេខ ០៤១សសរ.ពម ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការបង្កើតលេខាធិការដ្ឋាននៃក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង
- យោងតាមតម្រូវការចាំបាច់របស់ក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដើម្បីជានាសណ្តាប់ធ្នាប់សង្គម សុខុមាលភាពសាធារណៈ កាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចវប្បធម៌ ប្រពៃណីជាតិ និងជំរុញឱ្យមានការប្រកួតប្រជែងប្រកបដោយសុចរិត។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលមានកម្រិតអេតាណុលលើសពី ៣ ភាគរយ នៃបរិមាណ/ចំណុះ តាមគ្រប់ប្រភេទ គ្រប់ទម្រង់ និងគ្រប់មធ្យោបាយ រួមទាំងតាមមធ្យោបាយឌីជីថល នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។

ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

១- មិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលមានភ្ជាប់សេចក្តីបរិយាយបំផ្លើសខុសពីការពិត។

២- មិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលមានលក្ខណៈអូសទាញ ដូចជាការប្រើប្រាស់រូបភាពទទួលទានគ្រឿងស្រវឹង ដើម្បីលើកកម្ពស់សមត្ថភាពផ្លូវភេទ ឬភាពទាក់ទាញនាំទៅរកទំនាក់ទំនងផ្លូវភេទ ជាដើម។

៣- មិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្ម ឃោសនា និងការផ្សព្វផ្សាយលក់ផលិតផលគ្រឿងស្រវឹង ដោយយកទស្សនិកជនឱ្យទទួលទានគ្រឿងស្រវឹង នៅលើឆាកកម្មវិធីនានា។

៤- មិនអនុញ្ញាតឱ្យពិធីករ ពិធីការិនីបរិយាយ ឬបង្ហាញសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយលក់ផលិតផលគ្រឿងស្រវឹងតាមរយៈមធ្យោបាយជំរុញ និងលើកទឹកចិត្តឱ្យទទួលទានគ្រឿងស្រវឹងនៅតាមឆាកកម្មវិធីនានា។

៥- មិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្ម និងផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹងផ្តោតលើគោលដៅអនីតិជន និង/ឬយកអនីតិជនផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។

៦- មិនអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ឬការផ្សព្វផ្សាយលក់ផលិតផលគ្រឿងស្រវឹងនៅចន្លោះម៉ោង ១៨:០០នាទី ដល់ម៉ោង ២០:០០នាទី តាមស្ថានីយទូរទស្សន៍ និងស្ថានីយវិទ្យុគ្រប់ប្រភេទ លើកលែងតែការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយលក់ផលិតផលគ្រឿងស្រវឹងនោះ ដោយគ្រាន់តែបង្ហាញរូបសញ្ញា ឬឈ្មោះផលិតផល ឬអានឈ្មោះផលិតផលគ្រឿងស្រវឹងតែប៉ុណ្ណោះ។

៧- មិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង គ្រប់ប្រភេទតាមគ្រប់ទម្រង់ និងគ្រប់មធ្យោបាយផ្សព្វផ្សាយចម្ងាយតិចជាង ២០០ម៉ែត្រ នៅជុំវិញបរិវេណទីតាំងមួយចំនួន ជាអាទិ៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសាសនា មណ្ឌលវប្បធម៌ប្រវត្តិសាស្ត្រ និងអាកាសយានដ្ឋានអន្តរជាតិ។

៨- ជៀសវាងការប្រើប្រាស់រូបភាពហិង្សា អាសអាភាស ឬអាក្រាតកាយដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណីជាតិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ។

៩- ត្រូវដាក់សារអប់រំលើរាល់ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ទម្រង់ និងគ្រប់ប្រភេទ ជាអាទិ៍ " ពិសាគ្រឿងស្រវឹងសូមកុំបើកបរ " ឬ " ទទួលទានគ្រឿងស្រវឹងដោយការទទួលខុសត្រូវ " ដែលអាចអាន ឬមើលឃើញច្បាស់ មានទំហំ ១/៤ នៃទំហំផ្សាយពាណិជ្ជកម្ម។

១០- ហាមឃាត់ការប្រើវត្ថុ អត្តសញ្ញាណ និមិត្តសញ្ញា ម៉ាកផលិតផល ឧបករណ៍ ហ្គេម រចនាបថ រូបភាព ពណ៌ ភ្លេង និងតួអង្គ (ទោះជាការពិតក្តី ឬ ប្រឌិតក្តីរាប់បញ្ចូលទាំងរូបតុក្កតា ឬតារាល្បីៗជាដើម) ដែលមានគោលដៅជាចម្បងទាក់ទាញអនីតិជនឱ្យទទួលទានគ្រឿងស្រវឹង។

១១- ហាមឃាត់ការបង្ហាញពីការទទួលទានគ្រឿងស្រវឹងនៅមុនពេល ឬក្នុងពេលកំពុងបញ្ជារថយន្ត ឬយានយន្តគ្រប់ប្រភេទ។

១២- ហាមឃាត់ការបង្ហាញពីការទទួលទានគ្រឿងស្រវឹង គឺជាលក្ខខណ្ឌតម្រូវឱ្យសង្គមទទួលស្គាល់ ឬសម្រាប់ជោគជ័យក្នុងសង្គម ឬមោទនភាពជាតិ។

១៣- ហាមឃាត់បង្ហាញពីការទទួលទានគ្រឿងស្រវឹង សំដៅទៅលើស្ត្រីមានផ្ទៃពោះ ឬស្ត្រី ដែលបំបៅដោះទារក ឬបង្ហាញថា ម៉ាកគ្រឿងស្រវឹងណាមួយផ្តល់ផលប្រយោជន៍ផ្នែកសុខភាព ឬការព្យាបាល អាហារូបត្ថម្ភ (ផ្លូវចិត្ត ឬផ្លូវកាយ)។

១៤- ហាមឃាត់បង្ហាញពីការទទួលទានគ្រឿងស្រវឹង ឬគ្រឿងស្រវឹងម៉ាកជាក់លាក់ណាមួយអាចជួយក្នុងការទប់ស្កាត់ ឬព្យាបាលជំងឺ ឬស្ថានភាពណាមួយឡើយ លើកលែងតែមានច្បាប់អនុញ្ញាត។

១៥- ត្រូវគោរពចំពោះអ្នកទាំងឡាយដែលមានតំណមចំពោះផលិតផលគ្រឿងស្រវឹង រួមមានអ្នកកាន់សាសនា វប្បធម៌ អ្នកមានជំងឺ ស្ត្រីមានផ្ទៃពោះ ជាដើម។

១៦- ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង តាមទម្រង់អេឡិចត្រូនិក ឬឌីជីថល ឬបណ្តាញទំនាក់ទំនងសង្គម ត្រូវរចនាទំព័រថែងអំពីសារព្រមាន ហាមអនីតិជនចូលទស្សនា និង ដើម្បីធានាថា ការផ្សព្វផ្សាយពាណិជ្ជកម្មមិនមែនសម្រាប់អនីតិជន។

១៧- ហាមឃាត់ជាដាច់ខាតការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

អាជ្ញាធរមូលដ្ឋាន ត្រូវសហការផ្តល់លិខិតអនុញ្ញាតទីតាំងសម្រាប់ដាក់តាំងបង្ហាញប៉ាណូ អាហ្វីស ឆាកកម្មវិធីផ្សេងៗ ស្របតាមសមត្ថកិច្ចដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន តាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត (ក្រុង ស្រុក ខណ្ឌ) បន្ទាប់ពីសំណើនោះត្រូវបានផ្តល់ការអនុញ្ញាតពីក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ក.គ.ផ.ស. រួចហើយ។

**ប្រការ៥.-**

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ត្រូវសុំលិខិតអនុញ្ញាតតាមប្រព័ន្ធអនឡាញ ឬដោយផ្ទាល់ តាមរយៈយន្តការច្រកចេញចូលតែមួយរបស់លេខាធិការដ្ឋាន នៃក.គ.ផ.ស. រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដែលមានអាសយដ្ឋានស្ថិតនៅអគារលេខ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ (ក្នុងបរិវេណក្រសួងព័ត៌មាន)។

**ប្រការ៦.-**

រូបវន្តបុគ្គលមានដូចជា អាជីវករ KOL (Key Opinion Leader)។ល។ និង នីតិបុគ្គលដែលបាន និងកំពុងធ្វើការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង និង/ឬ ផ្តល់សេវាកម្មផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង តាមគ្រប់មធ្យោបាយ និងគ្រប់ទម្រង់ ត្រូវស្នើសុំការអនុញ្ញាតពីក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ក្រុមហ៊ុនភ្នាក់ងារផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលមិនទាន់បានចុះបញ្ជិកាអាជីវកម្ម ត្រូវស្នើសុំចុះបញ្ជិកាក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង តាមខ្លឹមសារដែលក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង បានអនុញ្ញាត។

ផុតរយៈពេលកំណត់នេះ ប្រសិនបើក្រុមហ៊ុន ឬបុគ្គលណាមិនអនុវត្តតាមខ្លឹមសារប្រកាសនេះ ហើយនៅតែធ្វើអាជីវកម្មផ្តល់សេវា ឬធ្វើការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងដោយគ្មានការអនុញ្ញាត នឹងត្រូវចាត់វិធានការតាមច្បាប់។

**ប្រការ៧.-**

រយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ លេខាធិការដ្ឋាននៃ ក.គ.ផ.ស. ដែលបានទទួលសំណើស្នើសុំផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាននិងឯកសារភ្ជាប់ដែលត្រូវបំពេញដោយអ្នកស្នើសុំ និងត្រូវផ្តល់លិខិតអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង តាមទម្រង់អេឡិចត្រូនិក ដែលអាចបោះពុម្ពបាន តាមគេហទំព័រចុះបញ្ជីដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជូនសាមីខ្លួន និងប្រធានក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។

**ប្រការ៨._**

កម្រៃសេវារដ្ឋបាលនៃការផ្ដល់លិខិតអនុញ្ញាតផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ត្រូវបង់នៅប្រកចេញចូលតែមួយរបស់លេខាធិការដ្ឋាន នៃក.គ.ផ.ស. ដោយអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងពាក់ព័ន្ធជាធរមាន ។

**ប្រការ៩._**

លេខាធិការដ្ឋាន នៃ ក.គ.ផ.ស. វិស័យឯកជន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**និងជាប្រធាន ក.គ.ផ.ស.**

ក្រសួងព័ត៌មាន ព្រះរាជាណាចក្រកម្ពុជា

**នេត្រ ភក្ត្រា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសុខាភិបាល
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យ សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានជំនាញចំណុះក្រសួងព័ត៌មាន
- មន្ទីរអង្គភាពជំនាញរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ